State of California
Department of Social Services

Noa Msg Doc No.: M44-211D 
Action : Deny
Issue: Homeless Ineligibility
Title: Temporary Shelter and/or Permanent Housing

Auto ID No.:
Source : 01-43
Issued by :
Reg Cite : 44-211.5

Use Form No. : NA 290 & NA Back 9
Original Date : 02-01-88
Revision Date : 07-29-10

MESSAGE:

ខណ្ឌបានបដិសេធពាក្យដាក់សុំជំនួយសំរាប់ការគ្មានផ្ទះសម្បែងរបស់លោកអ្នក
ដែលចុះកាលបរិច្ឆេទនៅ _______ សំរាប់ :

[ ] ទីជំរកជាបណ្តោះអសន្ន
[ ] ផ្ទះសម្បែងជាអចិន្ត្រៃយ៍

នេះគឺជាមូលហេតុ:

[ ] លោកអ្នកមិនមែនជាអ្នកគ្មានផ្ទះសម្បែងស្នាក់នៅ ។
ដើម្បីទទួលជំនួយសំរាប់ការគ្មានផ្ទះសម្បែង លោកអ្នកត្រូវតែមានលក្ខណៈណាមួយដូចច្បាប់ខាងក្រោមនេះ :
លោកអ្នកមិនមានទីកន្លែងផ្ទាល់ខ្លួនសំរាប់ស្នាក់នៅពេលយប់
ឬ លោកអ្នកស្នាក់នៅពេលយប់នៅក្នុងទីជំរកដែលជាកន្លែងស្នាក់នៅជាបណ្តោះអាសន្ន
ឬ ទីកន្លែងដែលលោកអ្នកកំពុងស្នាក់នៅ គឺជាកន្លែងដែលជាធម្មតាមនុស្សមិនស្នាក់នៅ ។
ឬ លោកអ្នកបានទទួលលិខិតឱ្យបង់ថ្លៃឈ្នួលផ្ទះ ឬឈប់ឱ្យនៅ ។

[ ] លោកអ្នកអាចទទួលជំនួយសំរាប់ការគ្មានផ្ទះសម្បែងបានតែម្តង នៅក្នុងពេលមួយជីវិត លើកលែងតែលោកអ្នកមានលក្ខណៈដូចការលើកលែងមួយ ។

[ ] លោកអ្នកបានរស់នៅជាមួយគ្រួសារមួយដែលនៅពេលនោះពួកគេបានទទួលជំនួយសំរាប់ ការគ្មានផ្ទះសម្បែង ។

[ ] គឺមិនមានភស្តុតាងអ្វីមួយដែលថាការគ្មានផ្ទះសម្បែងរបស់លោកអ្នកត្រូវបានបណ្តាលដោយសារការលើកលែងណាមួយក្នុងពេល១២ខែដូចមាននៅខាងក្រោម :
- o ការធ្វើបាបប្តីប្រពន្ធ
- o ទីកន្លែងមិនអាចរស់នៅបាន
- o ជម្ងឺផ្នែកពេទ្យ

[ ] លោកអ្នកបានទទួលជំនួយសំរាប់ការគ្មានផ្ទះសម្បែង ដោយសារតែការលើកលែងក្នុងពេល១២ខែរួចហើយ ។

[ ] ការគ្មានផ្ទះសម្បែងរបស់លោកអ្នកមិនបានបណ្តាលមកពីមហន្តរាយធម្មជាតិដែលបានប្រកាសដោយរដ្ឋ និងសហពន្ធនោះឡើយ ។

[ ] គឺមិនមានភស្តុតាងបង្ហាញថា លោកអ្នកបានមិនមានផ្ទះសម្បែងស្នាក់នៅសំរាប់ពេលទាំងអស់ដែលលោកអ្នកបានទទួលជំនួយចុងក្រោយសំរាប់ទីស្នាក់នៅជាបណ្តោះអាសន្នរបស់លោកអ្នក ។

[ ] លោកអ្នកមិនអាចទទួលជំនួយសំរាប់ទីស្នាក់នៅជាបណ្តោះអាសន្នបានទេពីព្រោះលោកអ្នកមិនបានទទួលប្រាក់ជំនួយ ។

[ ] លោកអ្នកមានប្រាក់ច្រើនជាង១០០ដុល្លារ ។ ដើម្បីទទួលជំនួយសំរាប់ការគ្មានផ្ទះសម្បែង លោកអ្នកមិនអាចមានធនធានអាចដូរជាប្រាក់ច្រើនជាង១០០ដុល្លារនោះទេ លើកលែងតែប្រាក់នោះនៅក្នុងគណនីមានកំហិត ។

[ ] លោកអ្នកមិនបានយល់ព្រមឱ្យយើងធ្វើការបញ្ជាក់ ពីភាពគ្មានផ្ទះសម្បែងរបស់លោកអ្នក ។ បើសិនជាលោកអ្នកយល់ព្រមឱ្យយើងធ្វើការបញ្ជាក់លើការគ្មានផ្ទះសម្បែង លោកអ្នកប្រហែលជាអាចទទួលជំនួយសំរាប់ទីស្នាក់នៅជាបណ្តោះអាសន្ន ។

[ ] លោកអ្នកត្រូវតែបង្ហាញភស្តុតាងថា លោកអ្នកកំពុងស្វែងរកផ្ទះសម្បែងជាអចិន្ត្រៃយ៍ ។ លោកអ្នកមិនទាន់បានបង្ហាញភស្តុតាង ។ លោកអ្នកនឹងលែងបានទទួលជំនួយសំរាប់ទីស្នាក់នៅជាបណ្តោះអាសន្នជាបន្តទៅទៀត ។

[ ] លោកអ្នកមិនមានទីកន្លែងសំរាប់រស់នៅជាអចិន្ត្រៃយ៍ ។

[ ] លោកអ្នកអាចជួលផ្ទះតែពីម្ចាស់ទ្រព្យសម្បត្តិ ឬអ្នកចាត់ចែងទ្រព្យសម្បត្តិដែលជាអ្នកធ្វើការឱ្យម្ចាស់ផ្ទះនោះ ។

[ ] ទីកន្លែងដែលលោកអ្នករកបានសំរាប់រស់នៅមានតម្លៃថ្លៃហួស ។ វាមានតម្លៃ $________ ។ ដើម្បីទទួលជំនួយសំរាប់ផ្ទះសម្បែងជាអចិន្ត្រៃយ៍ កន្លែងដែល លោកអ្នករកបានសំរាប់រស់នៅមិនអាចមានតម្លៃច្រើនជាង៨០ភាគរយនៃសរុបប្រាក់ចំណូលក្នុងគ្រួសារប្រចាំខែរបស់លោកអ្នកឡើយ ។ ចំនួន៨០ភាគរយនៃសរុបប្រាក់ចំណូលក្នុងគ្រួសារប្រចាំខែរបស់លោកអ្នកត្រូវបានគិតបង្ហាញនៅលើសេចក្តីប្រកាសនេះ ។

[ ] ចំនួនជំនួយសំរាប់ការគ្មានផ្ទះសម្បែងមិនអាចគ្រប់គ្រាន់សំរាប់ចំនួនសរុបប្រាក់ឈ្នួលផ្ទះជំពាក់ពីមុនមកទេ ។

[ ] ចំនួនប្រាក់ឈ្នួលផ្ទះជំពាក់ពីមុនមករបស់លោកអ្នកគឺមានច្រើនជាង៨០ភាគរយនៃសរុបប្រាក់ចំណូលក្នុងគ្រួសារប្រចាំខែរបស់លោកអ្នក ។ (សរុបប្រាក់ចំណូលក្នុងគ្រួសារប្រចាំខែរបស់លោកអ្នកត្រូវបានគិតបង្ហាញនៅខាងក្រោម)

[ ] លោកអ្នកមិនបានផ្តល់សំបុត្របង់ថ្លៃឈ្នួលផ្ទះ ឬសំបុត្រឈប់នៅ ។

[ ] ការបណ្តេញចេញពីផ្ទះរបស់លោកអ្នកគឺបណ្តាលមកពីមូលហេតុផ្សេងក្រៅពីការមិនបង់ថ្លៃឈ្នួលផ្ទះ ។

[ ] ការបណ្តេញចេញពីផ្ទះរបស់លោកអ្នកគឺបណ្តាលមកពីការមិនបង់ថ្លៃឈ្នួលផ្ទះ ហើយដែលមិនមែនបណ្តាលមកពីភាពពិបាកផ្នែកប្រាក់កាសដែលហួសពីសមត្ថភាពរបស់លោកអ្នកនោះឡើយ ។

[ ] លោកអ្នកមិនយល់ព្រមឱ្យយើងធ្វើការបញ្ជាក់លើលិខិតឱ្យបង់ថ្លៃឈ្នួលផ្ទះ ឬលិខិតឈប់នៅ ។

សរុបប្រាក់ចំណូលក្នុងផ្ទះសម្បែងប្រចាំខែសំរាប់ខែ ______

$ ______

x .80

សរុបចំនួនថ្លៃផ្ទះសម្បែងរបស់លោកអ្នកដែលអាចមានតម្លៃ (៨០% នៃចំនួនសរុបប្រាក់ចំណូលក្នុងផ្ទះសម្បែងប្រចាំខែ) : =$______

INSTRUCTIONS: Use to deny a request for homeless assistance for temporary shelter, permanent housing and rent arrearages.

Complete the first blank on page one with the date homeless aid was requested and check the appropriate box(es) to inform the applicant.

This message replaces M44-211D dated 11-21-06.

file : lchurch/MSERIES/M.44211D